របាយការណ៍សង្ខេបរបស់ ម.ស.ម.ក ស្តីពីកំណែទម្រង់សន្តិសុខ

សេចក្តីផ្តើម៖

របាយការណ៍សង្ខេបនេះផ្តល់នូវទិដ្ឋភាពទូទៅខ្លះៗនៃក្តីបារម្ភនាពេលថ្មីៗនេះទាក់ទិននឹងយោធា និងនគរបាលនៅក្នុងព្រះរាជាណាចក្រកម្ពុជា (“កម្ពុជា”) អំពាវនាវឲ្យមានកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីកំណែទម្រង់សន្តិសុខ និង ផ្តល់អនុសាសន៍មួយចំនួនដើម្បីជួយសម្រួលដល់កិច្ចដំណើរការនេះ។ របាយការណ៍សង្ខេបនេះត្រូវបានរៀបរៀងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា(“ម.ស.ម.ក”) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅកម្ពុជា។

កងទ័ពៈ

នៅពេលសង្គ្រាមទ័ពឈ្លបប្រឆាំងនឹងខ្មែរក្រហមចុងក្រោយបញ្ចប់នៅក្នុងឆ្នាំ១៩៩៨ និងការប្រយុទ្ធរវាងក្រុមប្រឆាំងត្រូវបានឃើញជាលើកចុងក្រោយនៅក្នុងឆ្នាំ១៩៩៧ ប្រទេសកម្ពុជាមិនបានស្ថិតក្នុងដាននៃសង្គ្រាមនៅលើទឹកដីរបស់ខ្លួនអស់ពេលជាងមួយទសវត្សរ៍មកហើយ។ ប៉ុន្តែទាហានស្លៀកពាក់ឯកសណ្ឋានកងទ័ព និងប្រើប្រាស់កាំភ្លើងនៅតែឃើញមានទូទាំងប្រទេស។ ជាញឹកញាប់ កងទ័ពជាប់ពាក់ព័ន្ធនឹង (១) ការបណ្តេញប្រជាពលរដ្ឋចេញដោយហិង្សា ដូចជានៅបុរីកីឡាក្នុងរាជធានីភ្នំពេញកាលពីថ្ងៃទី៣ ខែមករា ឆ្នាំ២០១២[1] និង(២) ការបង្ក្រាបយ៉ាងធ្ងន់ធ្ងរលើក្រុមបាតុករ ជាឧទាហរណ៍ករណីថ្មីៗនៅខេត្តកំពង់ស្ពឺ ដែលកងទាហានប្រដាប់អាវុធមកពីយោធាភូមិភាគ៣ ត្រូវបានរាយការណ៍ថា[2] ជាក់ពង្រាយនៅតុលាការដែលអ្នកភូមិបានកំពុងតែតវ៉ារឿងដីធ្លី និងត្រូវបានគំរាមកំហែងបាញ់ដោយកាំភ្លើងវែងអាកា៤៧ និងកាំភ្លើងបាញ់ស្វ័យប្រវត្តិ ប្រសិនបើក្រុមអ្នកតវ៉ាមិនរំសាយទេនោះ។ ទោះបីជាមន្ត្រីកម្ពុជាបដិសេធថាមិនដឹងពីករណីនេះដោយថ្លែងថាពួកគេមិនដឹងថាអ្នកណាជាអ្នកចេញបញ្ជា ឬ អ្នកណាដែលបានដឹកនាំត្រួតត្រាកងទាហាននោះក្តី លោកឧត្តមសេនីយ៍ទោ គង់ ប៊ុនថន មេបញ្ជាការរងយោធាភូមិភាគ៣ បានអះអាងថាអាជ្ញាធរខេត្តកំពង់ស្ពឺបញ្ជាឲ្យកងទាហានទៅកាន់តុលាការ។[3] កាលពីថ្ងៃទី១៨ ខែមករា ឆ្នាំ២០១២ នៅខេត្តក្រចេះ មន្ត្រីយោធាបាន

---

[1] វិចារណកថាព័ត៌មានរបស់ម.ស.ម.ក ថ្ងៃទី៤ ខែមករា ឆ្នាំ២០១២ ‘ការបណ្តេញប្រជាពលរដ្ឋក្នុងតំបន់បុរីកីឡាកាលពីម្សិលមិញគឺជាការខកខានមិនបានគោរពតាម“មូលដ្ឋានសសរស្តម្ភបី”របស់គោលការណ៍សិទ្ធិមនុស្ស និងអាជីវកម្ម’។

[2] *ឌីខែមប៊ូឌែរដេលី* ‘អ្នកស្រី មួរ សុខហួរ ស្នើសហរដ្ឋអាមេរិកស៊ើបអង្កេតលើកងទ័ពនៅពេលបាតុកម្ម’ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២។

[3] *ឌីខែមប៊ូឌែរដេលី* ‘មេបញ្ជាការនិយាយថាអាជ្ញាធរបញ្ជាឲ្យដាក់ពង្រាយកម្លាំងទ័ព’ ចុះថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២។

ប្រើប្រាស់កាំភ្លើង (ដោយខុសច្បាប់) ក្នុងនាមជនស៊ីវិលទៀតផង។[4] បន្ថែមលើយុទ្ធសាស្ត្រដែលបានបង្ហាញឲ្យឃើញជាសាធារណៈបែបនេះ យោធាក៏ត្រូវបានបង្ហាញថាបានជាប់ពាក់ព័ន្ធក្នុងសកម្មភាពដ៏យង់ឃ្នងដូចជាក្នុងរឿងការកាប់ឈើខុសច្បាប់ ការបំភិតបំភ័យក្នុងការបោះឆ្នោត និងការរំលោភយកដីធ្លីនានា ព្រមទាំងករណីរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរជាច្រើនផ្សេងទៀត។

កងទ័ពមិនគួរត្រូវបានប្រើប្រាស់ក្នុងនាមជាជនស៊ីវិលនោះទេ ប៉ុន្តែគួរតែស្ថិតនៅក្នុងមូលដ្ឋានទាហានរបស់ខ្លួន ឬ តាំងមូលដ្ឋាននៅតាមព្រំដែន ដើម្បីជាការត្រៀមខ្លួនការពារប្រទេសជាតិតាមរយៈសកម្មភាពយោធា។ ការខ្វែងគំនិតគ្នានៅតែកើតមានជាមួយនឹងប្រទេសថៃដែលជាប្រទេសជិតខាងទាក់ទិននឹងការតាំងលំនៅដ្ឋានអចិន្ត្រៃយ៍នៅតាមដែនដីតំបន់ជុំវិញប្រាសាទព្រះវិហារ និងការគូសខ្សែបន្ទាត់ព្រំដែនកម្ពុជា-ថៃជាអចិន្ត្រៃយ៍[5] ថ្វីបើមានទំនាក់ទំនងទ្វេភាគីគួរឲ្យកក់ក្តៅចាប់តាំងពីការបោះឆ្នោតជ្រើសតាំងអ្នកស្រី យីងឡាក់ ស៊ីណាវ៉ាត្រា ដែលមកពីគណបក្សភឿថៃកាលពីថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០១១។ នៅខណៈដែលប្រទេសកម្ពុជាគួរតែគោរពសេចក្តីសម្រេចរបស់តុលាការយុត្តិធម៌អន្តរជាតិ ដែលបានសម្រេចកាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១១ និងគួរតែដកកងទ័ពរបស់ខ្លួនពីតំបន់ប្រាសាទព្រះវិហារ ជាការពិតណាស់ដែលកម្ពុជាត្រូវមានកម្លាំងទាហានការពារអធិបតេយ្យភាពដែនដីរបស់ខ្លួន តែមិនត្រូវធ្វើឲ្យស្ថានភាពរឹតតែតានតឹងលើភាគីណាមួយនៅព្រំដែននោះឡើយ។ កងទ័ពគួរតែការពារប្រទេសកម្ពុជា ដោយមានកងរាជអាវុធហត្ថជាអ្នកពិនិត្យមើលហើយមិនត្រូវមានកងទ័ពដើរតួក្នុងនាមជាជនស៊ីវិលនោះទេ។

ឆតរច្ឆាលៈ

កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០១២ ការសែតឌឺខែមបូឌែដេលី បានរាយការណ៍អំពីអត្រាកើនឡើងនៃបទល្មើសដែលគួរឲ្យព្រួយបារម្ភនៅក្នុងរាជធានីភ្នំពេញ ("អត្រានៃបទល្មើសកើនឡើងនៅរាជធានីភ្នំពេញក្នុងឆ្នាំ២០១១") ដោយផ្អែកលើរបាយការណ៍ថ្មីមួយដែលចេញផ្សាយដោយសាលារាជធានីភ្នំពេញកាលពីថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១២។ បទឧក្រិដ្ឋធ្ងន់ធ្ងរបានកើនឡើងប្រហែល២៥%ក្នុងឆ្នាំ២០១១ធៀបនឹងឆ្នាំ២០១០ (មនុស្សឃាតកើន២១% រំលោភសេពសន្ថវៈកើន២៤% ប្លន់ប្រដាប់អាវុធកើន៣១% ខណៈដែលបទមជ្ឈិមកើន១១៩%ធៀបនឹងឆ្នាំ២០១០)។ បទល្មើសគ្រឿងញៀនបានកើនឡើងក្នុងចំនួនយ៉ាងច្រើនដល់៣៦៤% ក្នុងនោះចាប់ខ្លួនបាន៨៤០ករណីចំពោះបទល្មើសគ្រឿងញៀនក្នុងឆ្នាំ២០១១។ បទល្មើសទាក់ទងនឹងគ្រឿងញៀនកើនឡើងគុណនឹងបីចាប់តាំងពីឆ្នាំ២០១០ ទោះបីជាមានការចាប់ខ្លួន ការដាក់ពន្ធនាគារ និងការប្រព្រឹត្ត

---

[4] សាលាកបត្រព័ត៌មានកម្រងឯកសារករណីសិក្សារបស់ម.ស.ម.ក ខែមករា ឆ្នាំ២០១២ ការប្រើប្រាស់អាវុធខុសច្បាប់ដោយមន្ត្រីយោធា '[ការប្រើប្រាស់អាវុធខុសច្បាប់ដោយមន្ត្រីយោធា]'។

[5] របាយការណ៍សង្ខេបរបស់ម.ស.ម.ក ខែកក្កដា ឆ្នាំ២០១១ '[ភាពមិនច្បាស់លាស់នៃព្រំដែន៖ របាយការណ៍សង្ខេបស្តីពីភាពតានតឹងនៅព្រំដែនកម្ពុជា-ថៃ]'។

ដោយបង្ខំសម្រាប់ជនល្មើសគ្រឿងញៀនយ៉ាងណាក្តី ក៏នៅតែមិនច្បាស់ថាអ្នកទាំងនោះទទួលបានការធ្វើឲ្យមាននីតិសម្បទាល្អឡើងវិញដើម្បីជានាថាពួកគេមិនប្រព្រឹត្តបទល្មើសជាថ្មីនោះឡើយ។

តួលេខបែបនេះអាចត្រូវបានបកស្រាយតាមវិធីពីរយ៉ាងគឺ៖ តួលេខនេះចង្អុលបង្ហាញពីការពុះពារួមគ្នារបស់នគរបាលចំពោះបទឧក្រិដ្ឋ និងបទឆ្លឹម ដែលទំនងជាលទ្ធផលនៃគោលនយោបាយភូមិឃុំសុវត្ថិភាពដែលស្ថិតក្រោមការពិភាក្សា[6] ដែលបានណែនាំយ៉ាងសម្ងាត់ដោយអង្គការនីតិប្រតិបត្តិ កាលពីឆ្នាំ២០១០ ដើម្បីប្រយុទ្ធប្រឆាំងនឹងចោរកម្ម អំពើប្លន់ ការប្រើប្រាស់គ្រឿងញៀន ល្បែងស៊ីសង អំពើហិង្សាក្នុងគ្រួសារ អំពើជួញដូរមនុស្ស និងការកាន់កាប់អាវុធខុសច្បាប់ ឬ ជាការចង្អុលបង្ហាញពីការកើនឡើងនៃកម្រិតបទល្មើសដែលគួរឲ្យព្រួយបារម្ភក្នុងរាជធានីភ្នំពេញ។ យ៉ាងណាក្តី មានតម្រូវការយ៉ាងច្បាស់លាស់ក្នុងការកាត់បន្ថយបទល្មើស និងបង្កើនសន្តិសុខសុវត្ថិភាពនៅក្នុងរាជធានីភ្នំពេញ ជាពិសេសដោយផ្អែកលើរបាយការណ៍ដែលមិនបានបញ្ជាក់ច្បាស់លាស់នៃការកើនឡើងក្នុងការប្រើប្រាស់អាវុធខុសច្បាប់នៅក្នុងរាជធានី។

នគរបាលត្រូវតែទទួលបានការផ្តល់អំណាចដោយអនុលោមតាមច្បាប់ ដែលបានអនុម័តយ៉ាងត្រឹមត្រូវដើម្បីអនុវត្តការកិច្ចរបស់ពួកគេ និងចាត់វិធានការទប់ទល់បទល្មើសឲ្យបានទូលំទូលាយជាងនេះនៅក្នុងរាជធានីភ្នំពេញ និងប្រទេសកម្ពុជា។ ប្រាក់បៀវត្សរបស់នគរបាលត្រូវតែបង្កើន ហេតុដូច្នេះពួកគេអាចបំពេញតួនាទីរបស់ខ្លួនដោយសេចក្តីថ្លៃថ្នូរ ដោយមិនចាំបាច់ត្រូវបង្ខំទទួលយកសំណូកពុករលួយពីអ្នកដែលងាយរងគ្រោះជាងខ្លួន។ នគរបាលក៏ត្រូវជានាថាអាចថែរក្សាសណ្តាប់ធ្នាប់សាធារណៈ និងថែរក្សាសន្តិភាពក្នុងនាទីជាអ្នកធានាសុវត្ថិភាព ដើម្បីផលប្រយោជន៍សង្គម ដែលខាងកងទ័ពថ្មីៗនេះបានបំពេញតួនាទីរបស់ខ្លួន។ ជាចុងក្រោយ នគរបាលត្រូវតែអាចចាត់វិធានការបន្ទាន់ ជាជាងរង់ចាំបទបញ្ជាពីមន្ត្រីជនជាន់ខ្ពស់ ឬ អ្នកនយោបាយដូចដែលបានឃើញនៅក្នុងករណីបាញ់ប្រហារនៅខេត្តក្រចេះ[7] ដូចនេះជនប្រព្រឹត្តបទល្មើសមិនរត់គេចខ្លួនបាន។

អនុសាសន៍៖

- គួរតែមានកិច្ចពិភាក្សាថ្នាក់ជាតិស្តីពីកំណែទម្រង់សន្តិសុខ
- កងទ័ពគួរតែតាំងមូលដ្ឋាននៅឯព្រំដែន ឬមូលដ្ឋានទ័ព និងមិនត្រូវប្រើប្រាស់ក្នុងបរិបទនៃជនស៊ីវិលទេ
- ឯកសណ្ឋានយោធាមិនគួរស្លៀកពាក់ជាជនស៊ីវិលទេ
- ការរំលោភបំពានសិទ្ធិមនុស្ស និងការប្រើប្រាស់អាវុធខុសច្បាប់ដោយកងទ័ពគួរតែត្រូវបានស៊ើបអង្កេតឲ្យបានត្រឹមត្រូវ
- កងរាជអាវុធហត្ថគួរតែពិនិត្យលើកងទ័ពឲ្យបានត្រឹមត្រូវ

---

[6] សាលាកបត្រស្តីពីការធ្វើចំណាត់ថ្នាក់ច្បាប់របស់ម.ស.ម.ក ខែមករា ឆ្នាំ២០១២ ‘គោលនយោបាយភូមិឃុំមានសុវត្ថិភាព’។

[7] វិចារណកថាព័ត៌មានរបស់ម.ស.ម.ក ថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០១២ ‘ការធ្វើអន្តរាគមន៍ដ៏គួរឲ្យស្ងាគមន៍របស់នាយករដ្ឋមន្ត្រីក្នុងករណីបាញ់ប្រហារនៅខេត្តក្រចេះបង្ហាញពីបារជ័យរបស់ស្ថាប័នមានសមត្ថកិច្ច’។

- នគរបាលគួរតែត្រូវបានអនុញ្ញាតឲ្យថែរក្សាសណ្តាប់ធ្នាប់សាធារណៈជាជាងយោធា
- នគរបាលគួរតែត្រូវបានអនុញ្ញាតឲ្យចាត់វិធានការបន្ទាន់ដើម្បីដោះស្រាយកម្រិតនៃការកើនឡើងបទល្មើស
- ប្រាក់បៀវត្សនគរបាលគួរតែត្រូវបានបង្កើន ហេតុដូចនេះនគរបាលមិនត្រូវបង្ខំប្រព្រឹត្តអំពើពុករលួយ
- កិច្ចខិតខំក្នុងការដោះស្រាយបទល្មើសគួរតែត្រូវបានអនុវត្តឲ្យស្របតាមច្បាប់ដែលបានពិភាក្សាដេញដោលត្រឹមត្រូវជាជាងអនុវត្តតាមតែគោលនយោបាយរបស់អង្គការនីតិប្រតិបត្តិដូចជាគោលនយោបាយភូមិឃុំមានសុវត្ថិភាព។